**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃ១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុវិទ្ធី និងលោក គួ គក្តី ។ គេហទំព័រ www.kla.asia

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងធានាឱ្យការគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង ស្រុក ប្រកបដោយគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាព ដើម្បីសម្រេចនូវការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់និងធ្វើប្រតិភូកម្ម។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ស្របតាមមាត្រា៥២នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរដ្ឋបាលក្រុង ស្រុកទាំងអស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ត្រូវបានរៀបចំឡើងដោយផ្អែកលើគោលការណ៍ជាមូលដ្ឋាននៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុកនេះរួមមាន៖

១. ការរៀបចំនិងការអនុវត្តថវិកា

២. ប្រព័ន្ធគណនេយ្យ

៣. របាយការណ៍ហិរញ្ញវត្ថុ

៤. ទ្រព្យសម្បត្តិ និង

៥. សវនកម្មគណនី និងសវនកម្មប្រតិបត្តិការ។

**មាត្រា ៥.-**

ក្រុមប្រឹក្សាសង្កាត់ចំណុះក្រុងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យនិងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាក្រុង។

ក្រុមប្រឹក្សាក្រុងត្រូវធ្វើប្រតិភូកម្មមុខងារ ភារកិច្ច រួមទាំងធនធានសមស្របទៅឱ្យក្រុមប្រឹក្សាសង្កាត់ក្នុងក្រុងរបស់ខ្លួន។

សង្កាត់ចំណុះក្រុងត្រូវមានថវិការបស់ខ្លួនស្ថិតនៅក្នុងថវិការបស់រដ្ឋបាលក្រុង។ ចៅសង្កាត់របស់ក្រុងជាអាណាប័កផ្ទេរសិទ្ធិពីអភិបាលនៃគណៈអភិបាលក្រុងចំពោះថវិការបស់ខ្លួន។

**មាត្រា ៦.-**

រដ្ឋបាលក្រុង ស្រុកនីមួយៗត្រូវរៀបចំ អនុម័ត និងអនុវត្តក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់ខ្លួន។



ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុវិទ្ធី និងលោក ត្វ តក្តី ។ គេហទំព័រ www.kla.asia

ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម គឺជាឯកសារគ្រោងចំណាយរបស់រដ្ឋបាលក្រុង ស្រុកសម្រាប់រយៈពេលមិនតិចជាង៣ឆ្នាំ និងមិនលើសពី៥ឆ្នាំ ដោយត្រូវមានការព្យាករដែលមានលក្ខណៈប្រាកដប្រជាលើមូលដ្ឋានចំណូល និងវិធាននៃការបែងចែកចំណូលទៅតាមខ្ទង់ចំណាយនានារបស់រដ្ឋបាលក្រុង ស្រុក។

ទម្រង់បែបបទសម្រាប់ការរៀបចំនិងការអនុម័តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ៧.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចេញសេចក្ដីណែនាំស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាដល់រដ្ឋបាលក្រុង ស្រុក ដើម្បីឱ្យរដ្ឋបាលក្រុង ស្រុករៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួនបានទាន់ពេលវេលា។

## ជំពូកទី២

## ការរៀបចំនិងការអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក

### ផ្នែកទី១

### ចំណូល ចំណាយរបស់រដ្ឋបាលក្រុង ស្រុក

**មាត្រា ៨.-**

ថវិការបស់រដ្ឋបាលក្រុង ស្រុកជាឯកសារគតិយុត្តដែលគ្រោង និងអនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាននិងបន្ទុកដែលត្រូវចំណាយរបស់រដ្ឋបាលក្រុង ស្រុក និងមានចរិតលក្ខណៈតុល្យភាព។

ឆ្នាំថវិការបស់រដ្ឋបាលក្រុង ស្រុកចាប់ផ្ដើមពីថ្ងៃទី០១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។

ថវិការបស់រដ្ឋបាលស្រុកត្រូវរួមបញ្ចូលរាល់ចំណូល ចំណាយរបស់រដ្ឋបាលស្រុកដោយមិនគិតដល់ប្រភពដើម ឬ ចរិតលក្ខណៈឡើយ។

ថវិការបស់រដ្ឋបាលក្រុងត្រូវរួមបញ្ចូលរាល់ចំណូល ចំណាយទាំងអស់របស់រដ្ឋបាលក្រុង និងសង្កាត់នានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយមិនគិតដល់ប្រភពដើម ឬចរិតលក្ខណៈឡើយ។

ថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវឆ្លុះបញ្ចាំងរាល់ការចំណាយជាអាទិភាពនៃផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលក្រុង ស្រុក រួមទាំងតម្រូវការចាំបាច់របស់ឃុំ សង្កាត់នៅក្នុងក្រុង ស្រុក។

**មាត្រា ៩.-**

ថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវបានរៀបចំឡើងជាពីរផ្នែក ៖

- ផ្នែកទី១ : ចំណូល និងចំណាយចរន្ត
- ផ្នែកទី២ : ចំណូល និងចំណាយមូលធន។

ចំណូលសរុបត្រូវមានតុល្យភាពទៅនឹងចំណាយសរុប។ ក្នុងពេលរៀបចំនិងកែតម្រូវថវិកា អតិរេកក្នុងផ្នែកទី១ ត្រូវបានប្រើប្រាស់ជាគុណប្រយោជន៍ក្នុងផ្នែកទី២។



ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុរិទ្ធី និងលោក គូ គត្តី ។ គេហទំព័រ www.kla.asia

ចំណូលមូលធនមិនត្រូវបានប្រើប្រាស់សម្រាប់ធ្វើហិរញ្ញប្បទានដល់ចំណាយចរន្តឡើយ លើកលែងតែមានការអនុញ្ញាតដោយបទប្បញ្ញត្តិដោយឡែក ។

**មាត្រា ១០.-**

ការរៀបចំគម្រោងចំណូល និងចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវធ្វើឡើងដោយផ្អែកតាមទម្រង់ និងចំណាត់ថ្នាក់ថវិកាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ១១.-**

ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវបានកំណត់ និងប្រមូលតាមបទប្បញ្ញត្តិដោយឡែក ។

ការចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវបានគ្រប់គ្រងនិងអនុវត្តទៅតាមខ្លឹមសារដូចបានចែងនៅក្នុងជំពូកទី៥នៃអនុក្រឹត្យនេះ ។

## ផ្នែកទី២

## ការរៀបចំ និងការអនុម័តថវិការបស់រដ្ឋបាលក្រុង ស្រុក

**មាត្រា ១២.-**

គម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុកនីមួយៗដោយផ្អែកលើមូលដ្ឋានផែនការយុទ្ធសាស្ត្រថវិកា ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដែលអនុម័តដោយក្រុមប្រឹក្សាក្រុង ស្រុក ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវធានាថា គម្រោងថវិកាប្រចាំឆ្នាំនីមួយៗបានដាក់បញ្ចូលនូវគម្រោង ឬកម្មវិធីដែលអនុវត្តមិនទាន់ចប់នៅដំណាច់ឆ្នាំថវិកាកន្លងទៅ ដើម្បីបន្តអនុវត្តក្នុងថវិកានៃឆ្នាំបន្ទាប់ស្របតាមក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដែលបានធ្វើបច្ចុប្បន្នកម្ម និងត្រូវបានក្រុមប្រឹក្សាក្រុង ស្រុកអនុម័តរួចហើយ ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវពិគ្រោះយោបល់ជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុង ស្រុក ដើម្បីសម្របសម្រួលជាមួយនឹងផែនការសកម្មភាព និងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នដែលផ្តល់សេវា សម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីជំរុញឱ្យការអនុវត្តផែនការអភិវឌ្ឍន៍របស់រដ្ឋបាលក្រុង ស្រុកអាចសម្រេចបានប្រកបដោយប្រសិទ្ធភាព ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវដាក់ជូនកិច្ចប្រជុំគណៈអភិបាលនូវសេចក្តីព្រាងផែនការយុទ្ធសាស្ត្រនិងគម្រោងថវិកា ដើម្បីពិនិត្យនិងផ្តល់យោបល់ជូនក្រុមប្រឹក្សា ។

អភិបាលនៃគណៈអភិបាលខេត្តទទួលបានប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវផ្តល់ការគាំទ្របច្ចេកទេសដល់រដ្ឋបាលក្រុង ស្រុកលើការរៀបចំគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុកដោយមានជំនួយពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត និងទីចាត់ការហិរញ្ញវត្ថុខេត្ត ។



ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុរិទ្ធី និងលោក តូ តក្កី ។ គេហទំព័រ www.kla.asia

**មាត្រា ១៣.-**

ក្រោយពីបានទទួលតួលេខវិភាជន៍អំពីមូលនិធិសង្កាត់សម្រាប់ឆ្នាំបន្ទាប់ ក្រុមប្រឹក្សាក្រុងត្រូវកំណត់ថវិកាសម្រាប់សង្កាត់នានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងជូនដំណឹងដល់ក្រុមប្រឹក្សាសង្កាត់ ឱ្យបានទាន់ពេលវេលា។ សង្កាត់នីមួយៗត្រូវរៀបចំគម្រោងថវិការបស់ខ្លួន ដោយផ្អែកលើកញ្ចប់ថវិកាដែលបានកំណត់ដោយក្រុមប្រឹក្សាក្រុង និងដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិនិត្យ និងអនុម័ត ហើយបញ្ជូនត្រឡប់ទៅក្រុមប្រឹក្សាក្រុងវិញយ៉ាងយូរបំផុតត្រឹមថ្ងៃទី០១ ខែមិថុនា។ ការរៀបចំនិងការដាក់បញ្ចូល គម្រោងថវិកាសង្កាត់ទៅក្នុងគម្រោងថវិកាសរុបរបស់រដ្ឋបាលក្រុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានពិភាក្សាជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ១៤.-**

រដ្ឋបាលក្រុងត្រូវគាំទ្រដល់ការរៀបចំ និងការអនុម័តគម្រោងថវិការបស់សង្កាត់ ដោយផ្អែកលើផែនការអភិវឌ្ឍន៍ ផែនការយុទ្ធសាស្ត្រថវិកា កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុង និងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រុមប្រឹក្សាសង្កាត់នានាចំណុះក្រុង ត្រូវបានអញ្ជើញចូលរួម និងមានសិទ្ធិផ្តល់យោបល់ក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាក្រុងដើម្បីពិនិត្យ និងអនុម័តលើគម្រោងថវិការបស់រដ្ឋបាលក្រុង។

**មាត្រា ១៥.-**

អភិបាលនៃគណៈអភិបាលក្រុង ស្រុកក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនត្រូវធានាផ្តល់ឱកាស និងបង្កើតនូវយន្តការផ្សេងៗឱ្យប្រជាពលរដ្ឋនៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធនានាបានចូលរួមផ្តល់យោបល់ក្នុងដំណើរការរៀបចំគម្រោងថវិកា និងក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុកដើម្បីពិនិត្យ និងអនុម័តគម្រោងថវិកា ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុកនីមួយៗក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវគម្រោងថវិកាយ៉ាងតិច១សប្តាហ៍មុនពេលកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ដើម្បីប្រមូលយោបល់ចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន និងអ្នកពាក់ព័ន្ធនានា។ អភិបាលនៃគណៈអភិបាលក្រុងស្រុកត្រូវពិនិត្យមើល និងកែសម្រួលឡើងវិញនូវគម្រោងថវិកានេះដោយផ្អែកលើមតិយោបល់ចូលរួមរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា។ បន្ទាប់មកត្រូវបញ្ជូនគម្រោងថវិកាទៅក្រុមប្រឹក្សាក្រុង ស្រុកពិនិត្យ និងអនុម័ត។

ក្រុមប្រឹក្សាក្រុង ស្រុកត្រូវអនុម័តគម្រោងថវិកាតាមផ្នែកនិងតាមប្រភេទនីមួយៗនៅក្នុងកិច្ចប្រជុំជាសាធារណៈយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា និងបញ្ជូនទៅអភិបាលនៃគណៈអភិបាលខេត្ត និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តក្នុងសប្តាហ៍ទី១នៃខែកក្កដា។



ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុវិទ្ធី និងលោក គួ គន្ធី ។ គេហទំព័រ www.kla.asia

**មាត្រា ១៦.-**

បន្ទាប់ពីទទួលបានគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក អភិបាលនៃគណៈអភិបាលខេត្តត្រូវធានាថា មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តធ្វើការបូកសរុបគម្រោងថវិកាក្រុង ស្រុកទាំងអស់នៅក្នុងខេត្ត តាមទម្រង់ដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុកនីមួយៗត្រូវភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម ៖

- ផែនការយុទ្ធសាស្ត្រថវិកា និងឯកសារគតិយុត្តសម្រាប់គាំទ្រការព្យាករចំណូល ចំណាយថវិកា
- របាយការណ៍ស្តីពីការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាលើដំណើរការរៀបចំថវិកា។ ដោយឡែកសម្រាប់ក្រុង របាយការណ៍នេះត្រូវរួមបញ្ចូលនូវការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់
- របាយការណ៍ស្តីពីការអនុវត្តថវិកានៃឆ្នាំកំពុងដំណើរការ
- តារាងសង្ខេបកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងកម្មវិធីប្រតិបត្តិការលើការផ្តល់សេវាប្រចាំឆ្នាំ
- កំណត់ហេតុស្តីពីកិច្ចប្រជុំអនុម័តលើគម្រោងថវិការបស់ក្រុមប្រឹក្សាក្រុង ស្រុក។

**មាត្រា ១៧.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើប្រតិភូកម្មសមត្ថកិច្ចរបស់ខ្លួនជូនអភិបាល នៃគណៈអភិបាលខេត្តអមដោយប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ដើម្បីពិនិត្យអនុលោមភាពលើគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក ដោយមានការអញ្ជើញចូលរួមពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ដែលតំណាងឱ្យក្រុមប្រឹក្សាក្រុង ស្រុក ជាម្ចាស់ថវិកានិងអ្នកពាក់ព័ន្ធដទៃទៀត ដែលត្រូវកំណត់ដោយអភិបាលនៃ គណៈអភិបាលខេត្ត។

ការពិនិត្យអនុលោមភាពលើគម្រោងថវិកាក្រុង ស្រុកដូចបានកំណត់ក្នុងវាក្យខណ្ឌទី១ ខាងលើត្រូវធ្វើឡើងក្នុងអំឡុងខែសីហានៃឆ្នាំនីមួយៗ។

ក្នុងដំណើរការពិនិត្យអនុលោមភាពនេះ អភិបាលនៃគណៈអភិបាលខេត្តអមដោយប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តត្រូវពិនិត្យផ្ទៀងផ្ទាត់តាមគោលការណ៍ដូចខាងក្រោម ៖

- គម្រោងថវិកាបានរៀបចំឡើងទៅតាមទម្រង់ ចំណាត់ថ្នាក់ថវិកា បែបបទ និងនីតិវិធីដែលបានកំណត់
- មានការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាក្នុងដំណើរការរៀបចំថវិកា
- ការគ្រោងឥណទានថវិកាទៅតាមគោលការណ៍ចំណាយចាំបាច់
- គម្រោងថវិកាត្រូវគ្រោងតាមលក្ខខណ្ឌ ដែលភ្ជាប់ទៅនឹងការប្រើប្រាស់ធនធានពីប្រភពជាក់លាក់ដែលបានកំណត់ទុកជាមុន
- ធានាឱ្យមានតុល្យភាពពិតប្រាកដរវាងចំណូលនិងចំណាយថវិកា



ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុវិទ្ធិ និងលោក គួ គន្ធី ។ គេហទំព័រ www.kla.asia

- មានការពិភាក្សាអនុម័តគម្រោងថវិកាក្នុងកិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សា។

**មាត្រា ១៨.-**

ប្រសិនបើគម្រោងថវិកាត្រូវបានបំពេញតាមគោលការណ៍នៃការពិនិត្យ អនុលោមភាពដូចមានចែងក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ អភិបាលនៃគណៈអភិបាលខេត្តអមដោយប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ត្រូវបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកានិងចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អភិបាលនៃគណៈអភិបាលក្រុង ស្រុក។ សេចក្តីជូនដំណឹងត្រូវភ្ជាប់ជាមួយឯកសារដែលមានហត្ថលេខាសង្ខេបរបស់អភិបាលនៃគណៈអភិបាលខេត្ត និងបោះត្រាខេត្តលើទំព័រនីមួយៗ។

អភិបាលនៃគណៈអភិបាលខេត្តត្រូវចម្លងសេចក្តីជូនដំណឹងនិងឯកសារថវិកា ដែលមានបញ្ជាក់ទទួលស្គាល់ជូនដល់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត និងរតនាគារខេត្ត។

**មាត្រា ១៩.-**

ក្នុងករណីដែលអភិបាលនៃគណៈអភិបាលខេត្តអមដោយប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តពិនិត្យឃើញថាគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក ណាមួយមិនស្របទៅនឹងគោលការណ៍ពិនិត្យអនុលោមភាពដូចមានចែងក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ដើម្បីរៀបចំកែសម្រួលឡើងវិញតាមនីតិវិធីជាធរមានឱ្យបានមុនថ្ងៃទី១៥ ខែកញ្ញា។

អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវពិនិត្យកែតម្រូវគម្រោងថវិកាឡើងវិញស្របតាមការជូនដំណឹងរបស់អភិបាលនៃគណៈអភិបាលខេត្ត ហើយរៀបចំដាក់ជូនក្រុមប្រឹក្សាក្រុង ស្រុកពិនិត្យនិងអនុម័តឱ្យបានមុនថ្ងៃទី៣០ ខែកញ្ញា។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវធ្វើការបូកសរុប និងដាក់បញ្ចូលនូវគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុកទាំងអស់ដែលបានពិនិត្យអនុលោមភាពរួចហើយ ទៅក្នុងគម្រោងថវិកាសរុបនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាជំពូកមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

**មាត្រា ២០.-**

ក្រោយពីច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំចូលជាធរមាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចេញប្រកាសស្តីពីការបែងចែកកញ្ចប់ថវិកាទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗដើម្បីអនុវត្ត ដោយចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃមួយច្បាប់ អភិបាលនៃគណៈអភិបាលខេត្តមួយច្បាប់ ប្រធានរតនាគារខេត្តមួយច្បាប់ និងប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តមួយច្បាប់។

រដ្ឋបាលក្រុងត្រូវចេញដីកាធ្វើប្រតិភូកម្មថវិកានិងអាណាប័កផ្ទេរសិទ្ធិទៅឱ្យសង្កាត់នានាចំណុះក្រុងដើម្បីអនុវត្តថវិការបស់ខ្លួន។

**មាត្រា ២១.-**

ប្រសិនបើគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុកមិនត្រូវបានអនុម័តមុនថ្ងៃទី០១ ខែមករានៃឆ្នាំសម្រាប់ការិយបរិច្ឆេទដែលត្រូវអនុវត្តទេនោះ អភិបាលនៃគណៈអភិបាលក្រុង ស្រុកមានសិទ្ធិប្រមូលចំណូល


ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុវិទ្ធី និងលោក គួ គន្ធី ។ គេហទំព័រ www.kla.asia

តាមលក្ខខណ្ឌដែលបានអនុម័តដូចឆ្នាំមុន និងធានាចំណាយប្រចាំខែក្នុងកម្រិត១/១២នៃថវិកាឆ្នាំមុន រហូតដល់ថវិកាថ្មីត្រូវបានអនុម័ត ។

## ផ្នែកទី៣

## ការអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក

**មាត្រា ២២.-**

រដ្ឋបាលក្រុង ស្រុកនីមួយៗត្រូវបើកគណនីប្រាក់បញ្ញើនៅរតនាគារខេត្ត ដើម្បីបម្រើឱ្យប្រតិបត្តិការចំណូល ចំណាយថវិការបស់ខ្លួន ។

**មាត្រា ២៣.-**

ថវិការបស់រដ្ឋបាលក្រុង ស្រុកអាចនឹងត្រូវបានកែតម្រូវក្នុងអំឡុងឆ្នាំថវិកា ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃលក្ខខណ្ឌសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជះឥទ្ធិពលទៅលើការព្យាករដំបូងនៃចំណូល និងចំណាយ ។

ការកែតម្រូវថវិកាត្រូវរៀបចំ ពិនិត្យ អនុម័ត និងបញ្ជាក់ទទួលស្គាល់តាមនីតិវិធីដូចមានចែងក្នុងផ្នែកទី២ ជំពូកទី២នៃអនុក្រឹត្យនេះ ។

**មាត្រា ២៤.-**

ចលនាឥណទានផ្ទៃក្នុងនៃថវិការបស់រដ្ឋបាលក្រុង ស្រុក គឺជាការធ្វើនិយ័តកម្មឥណទានក្នុងប្រភេទចំណាយតែមួយ ដោយមិនធ្វើឱ្យប្រែប្រួលដល់ប្រភេទឥណទានថវិកានៃប្រភេទចំណាយ ឬមិនធ្វើឱ្យប្រែប្រួលប្រភេទគម្រោងវិនិយោគនៅក្នុងថវិកាដំបូងឡើយ ។ ចលនាឥណទានផ្ទៃក្នុងនៃថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចធ្វើប្រតិភូកម្មដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការធ្វើនិយ័តកម្មឥណទានរបស់ខ្លួនដើម្បីដោះស្រាយតម្រូវការក្នុងករណីចាំបាច់បន្ទាន់ ។

**មាត្រា ២៥.-**

ប្រភេទឥណទានថវិកានៃប្រភេទចំណាយ មិនបានគ្រោងទុកមិនត្រូវលើសពី៥% (ប្រាំភាគរយ)នៃថវិកាសរុប ។ ប្រភេទឥណទានថវិកានៃប្រភេទចំណាយមិនបានគ្រោងទុក អាចត្រូវបានប្រើប្រាស់សម្រាប់ធានាចំពោះចំណាយទាំងឡាយណា ដែលការវិភាជន៍មិនបានកំណត់ជាក់លាក់នៅពេលឥណទានត្រូវបានអនុម័ត ឬសម្រាប់ឥណទានបំពេញបន្ថែមជាគុណប្រយោជន៍ដល់ប្រភេទចំណាយផ្សេងៗទៀតរបស់រដ្ឋបាលក្រុង ស្រុក ។

ពេលមានតម្រូវការប្រើប្រាស់ប្រភេទឥណទានថវិកានៃប្រភេទចំណាយមិនបានគ្រោងទុក អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន ។

**មាត្រា ២៦.-**

គម្រោង ឬកម្មវិធីដែលអនុវត្តមិនទាន់ចប់នៅក្នុងឆ្នាំថវិកាត្រូវបានដាក់បញ្ចូលដើម្បីបន្តអនុវត្តនៅក្នុងគម្រោងថវិកាឆ្នាំបន្ទាប់ ដែលការគ្រោងចំណាយនេះស្ថិតនៅក្នុងកម្មវិធីវិនិយោគប្រចាំឆ្នាំលើមូលដ្ឋានកម្មវិធី


ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុរិទ្ធី និងលោក ត្វ តក្កី ។ គេហទំព័រ www.kla.asia

វិនិយោគបីឆ្នាំរំកិលដែលបានធ្វើបច្ចុប្បន្នកម្ម និងត្រូវបានក្រុមប្រឹក្សាពិនិត្យនិងអនុម័តរួចហើយ ។

**មាត្រា ២៧.-**

នៅដំណាច់ឆ្នាំថវិកា ៖

- អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំឆ្នាំ ព្រមទាំងព័ត៌មានចាំបាច់ផ្សេងៗទៀត ដើម្បីដាក់ជូនក្រុមប្រឹក្សាក្រុង ស្រុកពិនិត្យ អនុម័ត និងចេញសេចក្តីសម្រេចបញ្ជប់គណនីរដ្ឋបាលទៅតាមទម្រង់និងនីតិវិធីដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- គណនេយ្យករក្រុង ស្រុកនៅរតនាគារខេត្តត្រូវរៀបចំបិទបញ្ជីគណនេយ្យ និងធ្វើរបាយការណ៍គណនេយ្យ ។
- គណនេយ្យករក្រុង ស្រុក និងប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុក្រុង ស្រុក ត្រូវពិនិត្យ ផ្ទៀងផ្ទាត់ កែតម្រូវលេខនា និងឯកភាពលើរបាយការណ៍បិទបញ្ជីគណនេយ្យ ដើម្បីដាក់ជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុក ។

របាយការណ៍បិទបញ្ជីគណនេយ្យ និងរបាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំឆ្នាំ ត្រូវបង្ហាញនូវតួលេខអនុវត្តថវិកាជាក់ស្តែងរបស់រដ្ឋបាលក្រុង ស្រុក ទ្រព្យសម្បត្តិ និងស្ថានភាពរតនាគារនៅដំណាច់ឆ្នាំថវិការបស់រដ្ឋបាលក្រុង ស្រុកនីមួយៗ ។

សង្កាត់ចំណុះក្រុង ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំឆ្នាំរបស់ខ្លួន និងត្រូវផ្ញើជូនទៅរដ្ឋបាលក្រុង ។

**មាត្រា ២៨.-**

អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវដាក់ជូនកិច្ចប្រជុំគណៈអភិបាលនូវរបាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំឆ្នាំ ដើម្បីពិនិត្យ និងផ្តល់យោបល់ជូនក្រុមប្រឹក្សារបស់ខ្លួន ។

ក្រុមប្រឹក្សាក្រុង ស្រុកត្រូវអនុម័តលើរបាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំឆ្នាំ និងចេញសេចក្តីសម្រេចលើការបិទបញ្ជីថវិកាប្រចាំឆ្នាំដែលរួមមាន ៖

- ការបញ្ជាក់នូវចំណូល ចំណាយដែលសម្រេចបានក្នុងឆ្នាំថវិកា
- ការលុបចោលឥណទានថវិកាដែលមិនបានប្រើប្រាស់ និង
- ការបញ្ជាក់នូវគម្រោង ឬកម្មវិធីដែលអនុវត្តមិនទាន់ចប់ ហើយដែលត្រូវអនុវត្តបន្តនៅឆ្នាំបន្ទាប់ ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវបញ្ជូនរបាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំឆ្នាំ ដែលបានអនុម័តរួច និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាស្តីពីការបិទបញ្ជីថវិកាប្រចាំឆ្នាំទៅអភិបាលនៃគណៈអភិបាលខេត្ត និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ។អភិបាលនៃគណៈអភិបាលខេត្តត្រូវធានាថា មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តបូកសរុបរបាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំឆ្នាំជារបាយការណ៍រួម ផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុកលើរបាយការណ៍ស្តីពីការអនុវត្តថវិកា


ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុវិទ្ធិ និងលោក ឆ្នូ តក្តី ។ គេហទំព័រ www.kla.asia

ប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុកនីមួយៗដើម្បីពិនិត្យនីត្យានុកូលភាព និងបូកសរុបជាសេចក្តីព្រាងនៃការទូទាត់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និងដាក់បញ្ចូលទៅក្នុងជំពូកមួយនៃសេចក្តីព្រាងច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋ ដែលត្រូវដាក់សុំការពិនិត្យនិងអនុម័តពីរដ្ឋសភា និងព្រឹទ្ធសភា។

## ជំពូកទី៣

## ប្រព័ន្ធគណនេយ្យរបស់រដ្ឋបាលក្រុង ស្រុក

**មាត្រា ២៩.-**

ប្រព័ន្ធគណនេយ្យរបស់រដ្ឋបាលក្រុង ស្រុកត្រូវបានអនុវត្តដើម្បី ៖

- បញ្ជិការាល់ប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យទាន់ពេលវេលាដែលអាចជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់
- ផ្តល់មូលដ្ឋានសម្រាប់តាមដានការអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក។

ប្រព័ន្ធគណនេយ្យរបស់រដ្ឋបាលក្រុង ស្រុករួមមាន ៖

- **គណនេយ្យហិរញ្ញវត្ថុ** គឺការកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុ ដែលធ្វើឡើងតាមរយៈគណនីប្រាក់បញ្ញើរបស់រដ្ឋបាលក្រុង ស្រុកនៅរតនាគារខេត្ត និងដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ និងទាន់ពេលវេលាសម្រាប់ផ្តល់ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក។
- **គណនេយ្យថវិកា** គឺជាការតាមដាន និងរាយការណ៍អំពីការអនុវត្តថវិកា ដើម្បីធានាថាការចំណាយត្រូវបានធ្វើឡើងនៅកម្រិតឥណទានថវិកាដែលបានអនុញ្ញាត ហើយចំណូលត្រូវមានសង្គតិភាពជាមួយនឹងថវិកាដែលគ្រោង។

**មាត្រា ៣០.-**

គណនេយ្យហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ត្រូវផ្អែកលើមូលដ្ឋានគណនេយ្យបង្គរដោយអនុវត្តជាជំហានៗតាមលទ្ធភាព និងស្ថានភាពជាក់ស្តែង ដោយប្រើប្រាស់វិធីសាស្ត្របញ្ជិកាទ្វេភាគ។

បញ្ជិកាគណនេយ្យរបស់រដ្ឋបាលក្រុង ស្រុក ត្រូវអនុលោមតាមមាតិកាគណនីនៃប្លង់គណនេយ្យរបស់រដ្ឋបាលក្រុង ស្រុកដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា ៣១.-**

រតនាគារខេត្តត្រូវបំពេញមុខងារជាគណនេយ្យកររបស់រដ្ឋបាលក្រុង ស្រុក និងត្រូវអនុវត្តភារកិច្ចទាំងឡាយដូចខាងក្រោម ៖

- ប្រមូលឬទទួលចំណូលរបស់រដ្ឋបាលក្រុង ស្រុក
- ទូទាត់ចំណាយដែលបានចេញអាណត្តិដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក និងចៅសង្កាត់ក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិពីអភិបាលនៃគណៈអភិបាលក្រុងលើការអនុវត្តថវិការបស់សង្កាត់
- គ្រប់គ្រង និងបើកផ្តល់ថវិការបស់រដ្ឋបាលក្រុង ស្រុក



ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុវិទ្ធិ និងលោក នូ តក្កី ។ គេហទំព័រ www.kla.asia

- បញ្ជិកាប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុកស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា៣០នៃអនុក្រឹត្យនេះ
- រៀបចំរបាយការណ៍គណនេយ្យហិរញ្ញវត្ថុតាមកាលកំណត់
- ថែរក្សាទុកដាក់រាល់ឯកសារសក្ខីបត្រ និងបញ្ជីគណនេយ្យរបស់រដ្ឋបាលក្រុង ស្រុក។

**មាត្រា ៣២.-**

អភិបាលនៃគណៈអភិបាលក្រុង ស្រុកក្នុងនាមក្រុមប្រឹក្សាជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន ជាអ្នកបញ្ជាចំណូល សន្យាចំណាយ ជម្រះបញ្ជី និងបោះផ្សាយអាណត្តិ ដោយផ្អែកលើថវិការបស់រដ្ឋបាលក្រុង ស្រុកដែលបានអនុម័ត និងជាអ្នកគ្រប់គ្រង បង្កើត និងបញ្ឈប់គណនីរដ្ឋបាល។

អភិបាលនៃគណៈអភិបាលក្រុង ស្រុកអាចផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរក្នុងការសម្រេចលើថវិកាឱ្យទៅអភិបាលរងណាម្នាក់ជាអាណាប័កផ្ទេរសិទ្ធិដែលធ្វើសកម្មភាពដោយស្ថិតនៅក្នុងការទទួលខុសត្រូវ និងការត្រួតពិនិត្យរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក។

ចៅសង្កាត់ចំណុះក្រុង ជាអាណាប័កផ្ទេរសិទ្ធិពីអភិបាលនៃគណៈអភិបាលក្រុងចំពោះថវិកាដែលរដ្ឋបាលក្រុងបានប្រតិភូកម្មឱ្យសង្កាត់របស់ខ្លួន។

អាណាប័ក និងអាណាប័កផ្ទេរសិទ្ធិត្រូវតែតម្កល់គំរូហត្ថលេខាជាផ្លូវការដល់គណនេយ្យករមុខការ។

**មាត្រា ៣៣.-**

សិទ្ធិបញ្ជាចំណាយ និងការទូទាត់មិនត្រូវប្រគល់ឱ្យមនុស្សតែម្នាក់ទេ។

**មាត្រា ៣៤.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចអនុញ្ញាតដល់រដ្ឋបាលក្រុង ស្រុកក្នុងការគ្រប់គ្រងទាំងស្រុង ឬមួយចំណែកនៃប្រតិបត្តិការសាច់ប្រាក់តាមរយៈគណនីដែលបើកនៅធនាគារពាណិជ្ជប្រតិស្រុតណាមួយ។

**មាត្រា ៣៥.-**

រដ្ឋបាលក្រុង ស្រុកត្រូវបានអនុញ្ញាតឱ្យធ្វើការចំណាយទាំងឡាយដែលមានចំនួនទឹកប្រាក់នៅក្រោមកម្រិតមួយជាកំណត់តាមរយៈគណនីរជ្ជទេយ្យបុរេប្រទាន។

អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវតែងតាំងមន្ត្រីរបស់រដ្ឋបាលក្រុង ស្រុកឱ្យទទួលខុសត្រូវជារជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរង។

កម្រិតចំណាយ នីតិវិធីនៃការបើកគណនី និងការតែងតាំងរជ្ជទេយ្យករបុរេប្រទានត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រជ្ជទេយ្យករបុរេប្រទានត្រូវទទួលខុសត្រូវលើសុវត្ថិភាពសាច់ប្រាក់ ព្រមទាំងឯកសារសក្ខីបត្រពាក់ព័ន្ធ និងកត់ត្រារាល់ប្រតិបត្តិការ។ រជ្ជទេយ្យករបុរេប្រទានបំពេញភារកិច្ចក្រោមការត្រួតពិនិត្យរួមគ្នារបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក និងគណនេយ្យករក្រុង ស្រុក។



ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុវិទ្ធី និងលោក គួ គគ្គី ។ គេហទំព័រ www.kla.asia

**មាត្រា ៣៦.-**

អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវតែងតាំងមន្ត្រីរបស់រដ្ឋបាលក្រុង ស្រុកឱ្យទទួលបន្ទុកជាភ្នាក់ងារបើកផ្តល់ដែលទទួលខុសត្រូវលើការដកសាច់ប្រាក់ពីគណនីប្រាក់បញ្ញើនៅរតនាគារខេត្ត ដើម្បីធ្វើការទូទាត់ប្រាក់ឧបត្ថម្ភ ប្រាក់បៀវត្ស លាភការ និងប្រាក់បំណាច់ផ្សេងៗដល់ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក។ នីតិវិធីនៃការបង្កើត និងការតែងតាំងភ្នាក់ងារបើកផ្តល់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា ៣៧.-**

អភិបាលនៃគណៈអភិបាលក្រុង ស្រុកអាចបង្កើតរជ្ជទេយ្យចំណូល និងតែងតាំងរជ្ជទេយ្យករចំណូលឱ្យទទួលខុសត្រូវក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធតាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## របាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក

**មាត្រា ៣៨.-**

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំ ដើម្បី៖

- តាមដាន និងឆ្លុះបញ្ចាំងកិច្ចប្រតិបត្តិការចំណូល ចំណាយរបស់រដ្ឋបាលក្រុង ស្រុក ដោយប្រៀបធៀបជាមួយនឹងថវិកាដែលបានអនុម័ត
- វាយតម្លៃស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុកដោយផ្តល់នូវព័ត៌មានអំពីប្រភពនិងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ
- ផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាក្រុង ស្រុក គណៈអភិបាលក្រុង ស្រុក និងមន្ត្រីពាក់ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុកអាចវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តសកម្មភាពនានាដែលបានគ្រោង កំណត់បាននូវចំណុចខ្វះខាតដើម្បីចាត់វិធានការកែលម្អ
- អនុញ្ញាតឱ្យអាជ្ញាធរមានសមត្ថកិច្ច ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងទៀតតាមដាន ត្រួតពិនិត្យមើល និងវាយតម្លៃការអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក។

**មាត្រា ៣៩.-**

រដ្ឋបាលក្រុង ស្រុកត្រូវរៀបចំរបាយការណ៍ដូចខាងក្រោម៖

ក). របាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំត្រូវរៀបចំតាមទម្រង់របាយការណ៍ចំណូល ចំណាយ ផ្អែកតាមមាតិកាថវិកាដោយប្រៀបធៀបរវាងការអនុវត្តជាក់ស្តែងជាមួយនឹងថវិកាដែលបានអនុម័ត និងត្រូវបង្ហាញអំពីបញ្ហាប្រឈមនានាដែលបានជួបប្រទះក្នុងអំឡុងពេលនៃការអនុវត្តថវិកា។

ខ). របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរួមមាន៖



ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុវិទ្ធី និងលោក ទូ តក្កី ។ គេហទំព័រ www.kla.asia

- របាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំឆ្នាំ
- របាយការណ៍ផ្ទៀងផ្ទាត់គណនីប្រាក់បញ្ញើរបស់រដ្ឋបាលក្រុង ស្រុកនៅរតនាគារ ជាមួយនឹងបញ្ជីតាមដានថវិការបស់រដ្ឋបាលក្រុង ស្រុក
- របាយការណ៍ស្តីពីទ្រព្យសម្បត្តិ។

ដោយឡែកសង្កាត់ចំណុះក្រុងត្រូវរៀបចំ និងផ្ញើរបាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំទៅឱ្យរដ្ឋបាលក្រុង ដើម្បីតាមដានការអនុវត្តថវិការបស់សង្កាត់ និងបូកសរុបចូលទៅក្នុងរបាយការណ៍ថវិការបស់រដ្ឋបាលក្រុង។

របាយការណ៍ខាងលើត្រូវរៀបចំទៅតាមទម្រង់ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ៤០.-**

របាយការណ៍ហិរញ្ញវត្ថុត្រូវរៀបចំឡើងដោយគណនេយ្យករក្រុង ស្រុក និងត្រូវផ្ទៀងផ្ទាត់ជាមួយរបាយការណ៍គណនេយ្យថវិកាដែលគ្រប់គ្រងដោយរដ្ឋបាលក្រុង ស្រុក។

អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវដាក់របាយការណ៍ដូចមានចែងក្នុងមាត្រា៣៩នៃអនុក្រឹត្យនេះជូនកិច្ចប្រជុំគណៈអភិបាលដើម្បីពិនិត្យ និងផ្តល់យោបល់ជូនក្រុមប្រឹក្សាក្រុង ស្រុក និងដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុកដើម្បីពិនិត្យ និងអនុម័តទៅតាមប្រតិទិនដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រោយពីក្រុមប្រឹក្សាក្រុង ស្រុកបានអនុម័តរួច អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវ៖

- ផ្ញើរបាយការណ៍ទាំងនេះជូនអភិបាលនៃគណៈអភិបាលខេត្ត ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ដើម្បីបូកសរុប រួចហើយផ្ញើមកលេខាធិការដ្ឋានគ.ជ.អ.ប ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង
- ផ្សព្វផ្សាយរបាយការណ៍ទាំងនេះជាសាធារណៈ។

## ជំពូកទី៥

## ការគ្រប់គ្រងចំណាយរបស់រដ្ឋបាលក្រុង ស្រុក

### ផ្នែកទី១

### ខួបនៃការចំណាយ

**មាត្រា ៤១.-**

រដ្ឋបាលក្រុង ស្រុកត្រូវអនុវត្តចំណាយរបស់ខ្លួនក្នុងកម្រិតឥណទានស្របតាមជំពូក គណនី និងអនុគណនីដែលបានកំណត់នៅក្នុងថវិកាប្រចាំឆ្នាំដែលបានអនុម័ត។

ដំណើរការនៃចំណាយរបស់រដ្ឋបាលក្រុង ស្រុកត្រូវមានដំណាក់កាលទាំងឡាយដូចខាងក្រោម៖

១. ការសន្យាចំណាយ



ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុវិទ្ធិ និងលោក គួ គក្តី ។ គេហទំព័រ www.kla.asia

២. កិច្ចជម្រះបញ្ជី

៣. អាណត្តិកិច្ច និង

៤. ការទូទាត់។

**មាត្រា ៤២.-**

ការសន្យាចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវបានធ្វើឡើងដោយអាណាប័ក ឬអាណាប័កផ្ទេរសិទ្ធិនៃថវិការបស់រដ្ឋបាលក្រុង ស្រុក។

មុនពេលធ្វើការសន្យាចំណាយ អាណាប័ក ឬអាណាប័កផ្ទេរសិទ្ធិនៃថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវធានាថា៖

- គម្រោងចំណាយដែលបានស្នើពិតជាត្រឹមត្រូវទៅតាមប្រភេទថវិកា
- ភាពទំនេរនៃឥណទានដែលមាននៅក្នុងសៀវភៅថវិកា និងភាពត្រឹមត្រូវតាមមាតិកាថវិកា និង
- គម្រោងចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មត្រូវមាននៅក្នុងផែនការលទ្ធកម្ម។

គម្រោងចំណាយដែលត្រូវអនុវត្តលទ្ធកម្ម និងត្រូវបានសន្យាចំណាយរួចនោះ ត្រូវដំណើរការអនុវត្តតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈព្រមទាំងតាមវិធីសាស្ត្រ នីតិវិធី វិធាន និងបទប្បញ្ញត្តិលទ្ធកម្មសាធារណៈនានាជាធរមាន។

**មាត្រា ៤៣.-**

កិច្ចជម្រះបញ្ជីគឺជាការកំណត់នូវកាតព្វកិច្ចរបស់រដ្ឋបាលក្រុង ស្រុកដែលត្រូវជម្រះរដ្ឋទេយ្យបុរេប្រទាន និងទូទាត់ជូនអ្នកផ្គត់ផ្គង់ អ្នកទទួលការដែលបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌនានាដែលមានចែងក្នុងកិច្ចសន្យា។

ក្នុងកិច្ចជម្រះបញ្ជី អាណាប័ក ឬអាណាប័កផ្ទេរសិទ្ធិនៃថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវធានាថា៖

- សំណង់ ទំនិញ និងសេវាត្រូវបានប្រគល់ឬផ្តល់ត្រឹមត្រូវតាមកិច្ចសន្យា និង
- វិក្កយបត្រពិតជាត្រឹមត្រូវទៅនឹងចំនួន និងការងារអនុវត្តបាន។

**មាត្រា ៤៤.-**

បន្ទាប់ពីបញ្ចប់កិច្ចជម្រះបញ្ជី អាណាប័ក ឬអាណាប័កផ្ទេរសិទ្ធិនៃថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវពិនិត្យស្ថានភាពគណនីប្រាក់បញ្ញើថវិការបស់រដ្ឋបាលក្រុង ស្រុក ក្នុងករណីដែលមានលទ្ធភាពទូទាត់បាន ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ដោយភ្ជាប់ជាមួយឯកសារពាក់ព័ន្ធ បញ្ជូនទៅគណនេយ្យករក្រុង ស្រុក។

**មាត្រា ៤៥.-**

គណនេយ្យករត្រូវធ្វើការទូទាត់ដល់អត្ថគាហកដែលបានបញ្ជាក់ក្នុងអាណត្តិបើកប្រាក់។

មុនពេលទូទាត់ គណនេយ្យករក្រុង ស្រុកត្រូវធ្វើការត្រួតពិនិត្យនិងបញ្ជាក់លើចំណុចដូចខាងក្រោម៖

- ហត្ថលេខារបស់អាណាប័ក ឬអាណាប័កផ្ទេរសិទ្ធិនៅលើអាណត្តិបើកប្រាក់ពិតជាត្រឹមត្រូវ
- មន្ត្រីមុខការបានបញ្ជាក់ថា សម្ភារៈត្រូវបានទទួល ឬសេវាត្រូវបានផ្តល់ត្រឹមត្រូវតាមកិច្ចសន្យា
- វិក្កយបត្រ និងឯកសារទាំងឡាយដែលជាតម្រូវការនៃការទូទាត់ពិតជាត្រឹមត្រូវ



ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុវិទ្ធិ និងលោក ត្នូ តក្តី ។ គេហទំព័រ www.kla.asia

- ឥណទាយកពិតជាត្រឹមត្រូវតាមកិច្ចសន្យា
- សំណើទូទាត់ពិតជាត្រឹមត្រូវតាមប្រភេទចំណាយ និងមានឥណទានទំនេរគ្រប់គ្រាន់ក្នុងប្រភេទចំណាយនេះ
- ស្ថានភាពគណនីប្រាក់បញ្ញើរបស់រដ្ឋបាលក្រុង ស្រុកមានលទ្ធភាពទូទាត់បាន និង
- ឯកសារពាក់ព័ន្ធគ្រប់គ្រាន់ត្រឹមត្រូវ ។

ក្នុងករណីមិនបានបំពេញលក្ខខណ្ឌខាងលើគ្រប់គ្រាន់ គណនេយ្យករក្រុង ស្រុកមានសិទ្ធិផ្អាកការទូទាត់ ហើយជូនដំណឹងជាលាយល័ក្ខណ៍អក្សរជាបន្ទាន់ដល់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ដោយបញ្ជាក់ពីមូលហេតុ និងសំណូមពរបំពេញបន្ថែម ។

## ផ្នែកទី២

## កិច្ចលទ្ធកម្មសាធារណៈ

**មាត្រា ៤៦.-**

កិច្ចលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សាត្រូវអនុវត្តតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មសាធារណៈដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា ៤៧.-**

កិច្ចលទ្ធកម្មរបស់សង្កាត់ចំណុះរដ្ឋបាលក្រុង ត្រូវអនុវត្តដោយគណៈកម្មការលទ្ធកម្មសង្កាត់ ។ រដ្ឋបាលក្រុងមានភារកិច្ចតាមដានការអនុវត្តកិច្ចលទ្ធកម្មរបស់សង្កាត់ចំណុះរដ្ឋបាលក្រុង ។

## ជំពូកទី៦

## ទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង ស្រុក

**មាត្រា ៤៨.-**

ទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង ស្រុករួមមានពីរប្រភេទ ៖

- ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ
- ទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង រួមទាំងអំណោយផ្សេងៗ ។

**មាត្រា ៤៩.-**

ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ រដ្ឋបាលក្រុង ស្រុកមានសិទ្ធិគ្រប់គ្រង ប្រើប្រាស់ និងទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះ ហើយក្រុង ស្រុកត្រូវថែរក្សា ការពារឱ្យបានគង់វង្ស និងគ្មានសិទ្ធិលក់ដូរ ជួល ផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

**មាត្រា ៥០.-**

ទ្រព្យសម្បត្តិដែលរដ្ឋបាលក្រុង ស្រុករកបានដោយខ្លួនឯង ជាកម្មសិទ្ធិផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក ដែលរដ្ឋបាលក្រុង ស្រុកមានសិទ្ធិស្វ័យសម្រេចក្នុងការគ្រប់គ្រងនិងប្រើប្រាស់ ដើម្បីទាញយកផលចំណូលពី



ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុវិទ្ធី និងលោក គួ តក្តី ។ គេហទំព័រ www.kla.asia

ទ្រព្យសម្បត្តិទាំងនោះនៅក្នុងក្របខ័ណ្ឌដែលត្រូវបានកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៥១.-**

រដ្ឋបាលក្រុង ស្រុកមានសិទ្ធិលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង។

ការលក់ដូរ ឬការផ្ទេរកម្មសិទ្ធិ ឬការផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិដែលរដ្ឋបាលក្រុង ស្រុករកបានដោយខ្លួនឯង ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖

- ក្រុមប្រឹក្សាក្រុង ស្រុកត្រូវបង្កើតគណៈកម្មការមួយដើម្បីដំណើរការលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិ
- ដំណើរការលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិត្រូវធានាឱ្យមានតម្លាភាព និងបើកទូលាយដល់ការប្រកួតប្រជែងគ្នាជាសាធារណៈ
- ក្នុងការលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិ អភិបាលក្រុង ស្រុកត្រូវសម្រេចផ្អែកតាមអនុសាសន៍របស់គណៈកម្មការក្នុងនាមក្រុមប្រឹក្សាក្រុង ស្រុក។

**មាត្រា ៥២.-**

ការលក់ដូរ ឬការផ្ទេរកម្មសិទ្ធិ ឬការផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង ស្រុកដែលបានមកពីអំណោយត្រូវគោរពទៅតាមលក្ខខណ្ឌដែលបានព្រមព្រៀងរវាងម្ចាស់អំណោយ និងរដ្ឋបាលក្រុង ស្រុក។

ក្នុងករណីអំណោយគ្មានលក្ខខណ្ឌពីម្ចាស់អំណោយ ការលក់ដូរ ឬការផ្ទេរកម្មសិទ្ធិ ឬការផ្ទេរការប្រើប្រាស់ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងមាត្រា៥១នៃអនុក្រឹត្យនេះ។

**មាត្រា ៥៣.-**

រដ្ឋបាលក្រុង ស្រុកត្រូវធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិទាំងអស់ និងត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ ហើយត្រូវបញ្ជូនទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ដើម្បីបញ្ចូលក្នុងបញ្ជីសារពើភណ្ឌរួមនៃទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា ៥៤.-**

ទ្រព្យសម្បត្តិដែលសង្កាត់កំពុងកាន់កាប់ត្រូវចាត់ទុកជាទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង។ រដ្ឋបាលក្រុងត្រូវប្រគល់សិទ្ធិឱ្យសង្កាត់ចំណុះរដ្ឋបាលក្រុងប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះក្នុងនាមរដ្ឋបាលក្រុង និងដែលអាចដកហូតមកវិញបាន។

សង្កាត់មានសិទ្ធិគ្រប់គ្រង ប្រើប្រាស់ និងទាញយកផលចំណូលពីទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង ដែលបានប្រគល់ឱ្យ ហើយសង្កាត់ត្រូវថែរក្សា ការពារឱ្យបានគង់វង្ស និងគ្មានសិទ្ធិលក់ដូរ ជួល ផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋបាលក្រុងបានឡើយ។


ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុវិទ្ធី និងលោក ឆ្វ ឥត្ថិ ។ គេហទំព័រ www.kla.asia

## ជំពូកទី៧
## សវនកម្មគណនី និងសវនកម្មប្រតិបត្តិការរបស់ក្រុង ស្រុក

**មាត្រា ៥៥.-**

ក្រុមប្រឹក្សាក្រុង ស្រុកត្រូវធានាថា យន្តការត្រួតពិនិត្យផ្ទៃក្នុងដែលមានក្នុងប្រព័ន្ធគ្រប់គ្រងត្រូវបានអនុវត្តដើម្បីសម្រេចឱ្យបានតាមគោលដៅដូចខាងក្រោម ៖

- ប្រព័ន្ធគ្រប់គ្រងដែលបានបង្កើតមានលក្ខណៈគ្រប់គ្រាន់ សមស្រប និងមានប្រសិទ្ធភាព
- ធនធានត្រូវបានប្រើប្រាស់ស្របតាមថវិកាដែលបានអនុម័តព្រមទាំងស្របតាមច្បាប់ និងបទបញ្ញាជាធរមាន
- ធនធានត្រូវបានទុកដាក់ឱ្យបានត្រឹមត្រូវ មិនបាត់បង់ និងមិនប្រើប្រាស់ខុសគោលការណ៍
- ទិន្នន័យហិរញ្ញវត្ថុពិតប្រាកដត្រូវបានរៀបចំ និងលាតត្រដាងក្នុងរបាយការណ៍ ។

ក្រុមប្រឹក្សាក្រុង ស្រុក ត្រូវតែងតាំងមន្ត្រីមួយរូបរបស់រដ្ឋបាលក្រុង ស្រុកឱ្យទទួលបន្ទុកជាសវនករផ្ទៃក្នុង។ សវនករផ្ទៃក្នុងត្រូវមានភារកិច្ចជួយអភិបាលក្រុង ស្រុកក្នុងការត្រួតពិនិត្យជាប្រចាំលើការងារគ្រប់គ្រងហិរញ្ញវត្ថុថវិកា ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមានដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៥៦.-**

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុង ស្រុកជាកម្មវត្ថុសម្រាប់ធ្វើសវនកម្មរបស់ស្ថាប័នមានសមត្ថកិច្ច ។

គោលបំណងនៃសវនកម្ម គឺសំដៅធានាភាពជាក់លាក់ ត្រឹមត្រូវនៃព័ត៌មានហិរញ្ញវត្ថុ វាយតម្លៃការអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក ប្រព័ន្ធគ្រប់គ្រង និងនីតិវិធី ។ របាយការណ៍សវនកម្មដែលមានរួមបញ្ចូលនូវមតិយោបល់របស់ក្រុមប្រឹក្សាក្រុង ស្រុក ត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ៥៧.-**

គណនី និងប្រតិបត្តិការរបស់រដ្ឋបាលក្រុង ស្រុកអាចត្រូវធ្វើសវនកម្មដោយស្ថាប័នជាតិ ឬដោយសវនករឯករាជ្យតាមសំណូមពររបស់ដៃគូអភិវឌ្ឍន៍ដែលបានផ្តល់ហិរញ្ញប្បទានដល់រដ្ឋបាលក្រុង ស្រុក ។

**មាត្រា ៥៨.-**

អភិបាលនៃគណៈអភិបាលខេត្តត្រូវគាំទ្រជាប្រចាំនូវសវនកម្ម ដែលមានលក្ខណៈជាការពិគ្រោះយោបល់ដែលធ្វើឡើងតាមរូបភាពជាជំនួយបច្ចេកទេស និងមានលក្ខណៈជាការកសាងសមត្ថភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការដល់រដ្ឋបាលក្រុង ស្រុក ។

**មាត្រា ៥៩.-**

ប្រជាពលរដ្ឋមានសិទ្ធិពេញលេញក្នុងការពិនិត្យ តាមដានការអនុវត្តការងាររបស់ក្រុមប្រឹក្សា និងរដ្ឋបាលក្រុង ស្រុក ។ ក្នុងនាមក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវធានាថា ៖

- រាល់ព័ត៌មានស្តីពីសកម្មភាព និងគណនីរបស់រដ្ឋបាលក្រុង ស្រុកត្រូវបានផ្សព្វផ្សាយជាសាធារណៈ
- ការទទួលមតិសាធារណៈ និងការពិគ្រោះយោបល់ត្រូវបានអនុវត្តក្នុងដំណើរការការងាររបស់ខ្លួន



ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុរិទ្ធី និងលោក តូ គគ្គី ។ គេហទំព័រ www.kla.asia

- ប្រជាពលរដ្ឋត្រូវបានទទួលការលើកទឹកចិត្ត និងអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ។

## ជំពូកទី៨

## អន្តរប្បញ្ញត្តិ

**មាត្រា ៦០.-**

សម្រាប់ឆ្នាំ២០១២ ថវិការបស់រដ្ឋបាលសង្កាត់ចំណុះរដ្ឋបាលក្រុងត្រូវបន្តអនុវត្តតាមអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ និងអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្ដីពីមូលនិធិឃុំ សង្កាត់ ។

អតិរេកថវិការបស់រដ្ឋបាលសង្កាត់នៃឆ្នាំថវិកា២០១២ នឹងត្រូវផ្ទេរទៅឆ្នាំបន្ទាប់ ។

**មាត្រា ៦១.-**

នៅពេលដែលនីតិវិធីកសាងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលក្រុង និងសង្កាត់ក្នុងក្រុងមិនទាន់បានកែសម្រួល រដ្ឋបាលសង្កាត់ក្នុងក្រុងត្រូវរៀបចំ និងអនុវត្តថវិកាតាមរយៈថវិការបស់រដ្ឋបាលក្រុង ។

**មាត្រា ៦២.-**

កិច្ចលទ្ធកម្មរបស់សង្កាត់ចំណុះក្រុង ត្រូវអនុវត្តតាមវិធាន និងបទប្បញ្ញត្តិស្ដីពីលទ្ធកម្មឃុំ សង្កាត់រហូតដល់មានវិធាន និងបទប្បញ្ញត្តិថ្មីមកជំនួស ។

## ជំពូកទី៩

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ៦៣.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវដាក់ចេញនូវប្រកាស សេចក្ដីណែនាំ ដើម្បីអនុវត្តនូវបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងជំពូកទី១ ដល់ជំពូកទី៧នៃអនុក្រឹត្យនេះ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រោមការសម្របសម្រួលពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

## ជំពូកទី១០

## ទោសប្បញ្ញត្តិ

**មាត្រា ៦៤.-**

សមាជិកក្រុមប្រឹក្សា និងមន្ត្រីសាធារណៈគ្រប់ប្រភេទ និងគ្រប់ឋានៈដែលកំពុងបម្រើការងារ និងអ្នកដែលធ្លាប់បានបម្រើការងារកន្លងមក ហើយរកឃើញថា មិនបានគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនដែលបានប្រគល់ជូន នឹងត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន ដោយមិនគិតដល់ទោសព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ព្រមទាំងត្រូវសងបង់ចូលថវិការដ្ឋបាលក្រុង ស្រុកវិញនូវរាល់តម្លៃបាត់បង់ខូចខាតទ្រព្យសម្បត្តិ ឬប្រាក់កាសសាធារណៈរួមទាំងការប្រាក់លើតម្លៃបាត់បង់ខូចខាតដែលបង្កឡើងដោយកំហុសឆ្គងនេះ ។



ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុវិទ្ធី និងលោក គួ គង្គី ។ គេហទំព័រ www.kla.asia

## ជំពូកទី១១

## អវសានប្បញ្ញត្តិ

**មាត្រា ៦៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៦៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ប្រធានក្រុមប្រឹក្សាខេត្ត អភិបាលនៃគណៈអភិបាលខេត្ត ប្រធានក្រុមប្រឹក្សាក្រុង ស្រុក អភិបាលនៃគណៈអភិបាលក្រុង ស្រុក ប្រធានក្រុមប្រឹក្សាសង្កាត់ចំណុះក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ១៧ ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ស ខេង គាត ឈន់**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



ផ្តួចផ្តើមរៀបចំចងក្រង និងគ្រប់គ្រងដោយ លោក ពុទ្ធ សុរិទ្ធី និងលោក ទូ តក្តី ។ គេហទំព័រ www.kla.asia